# តារាងសម្លាប់មេរោគ
## សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន

**រៀបចំទឹកថ្នាំសម្លាប់មេរោគដោយប្រើទឹកអូសាវ៉ែល ប្រភេទប្រើក្នុងគ្រួសារ (កំហាប់ ៥,២៥%**

| | ថ្នាំសម្លាប់មេរោគ កម្រិតទាប<br>**100 PPM*** | ថ្នាំសម្លាប់មេរោគ កម្រិតមធ្យម<br>**1000 PPM*** | ថ្នាំសម្លាប់មេរោគ កម្រិតខ្ពស់<br>**5000 PPM*** |
|---|---|---|---|
| **ឧទាហរណ៍នៃផ្ទៃ និងឧបករណ៍ ដែលត្រូវសម្លាប់មេរោគ** | ក្រាសសិតសក់ ដងកាន់ និងឧបករណ៍សម្រាប់ជាងកាត់សក់ តុ កៅអី គ្រែ និងកន្លែងសម្ងួតក្រចក | អាងត្រាំជើង, កន្ត្រៃកាត់ក្រចក, កន្ត្រៃកាត់ស្បែកជុំវិញក្រចក, ក្បាលម៉ាស៊ីនកិនក្រចកធ្វើពីលោហៈ (អាចប្រើឡើងវិញបាន), ឧបករណ៍ចោះត្រចៀក, គម្របដាក់ទឹកថ្នាំសម្រាប់ប្រើតែម្តង, ដង្កៀប (សម្រាប់ដកសក់ ឬរោមចេញពីស្បែក ឬសម្រាប់បិទរោមភ្នែកសិប្បនិម្មិត) | ឧបករណ៍ខាត់ជើង/ឈូស ឧបករណ៍ញែចមុន ដែលមានចុងជារង្វង់ ក្បាលខាត់ស្បែកប្រភេទ Diamond Microdermabrasion និងប្រដាប់ចាប់ទាញរោមដែលដុះចូលក្នុងស្បែកចេញមកក្រៅ |
| **របៀបធ្វើ** | ទឹកថ្នាំអូសាវ៉ែល ២ មីលីលីត្រ (កន្លះស្លាបព្រាកាហ្វេ) ជាមួយទឹក ១ លីត្រ (៤ ពែង) | ទឹកថ្នាំអូសាវ៉ែល ១០ មីលីលីត្រ (២ ស្លាបព្រាកាហ្វេ) ជាមួយទឹក ៥០០ មីលីលីត្រ (២ ពែង) | ទឹកថ្នាំអូសាវ៉ែល ១២៥ មីលីលីត្រ (កន្លះពែង) ជាមួយទឹក ១ លីត្រ (៤ ពែង) |
| **រយៈពេលត្រាំ** | ១០ នាទី | ១០ នាទី | ១០ នាទី |
| **វិធីសម្ងួត** | សម្ងួតដោយខ្យល់ | លាងជម្រះ និងសម្ងួតដោយខ្យល់ | លាងជម្រះ និងសម្ងួតដោយខ្យល់ |

* កំហាប់គឺជាការប៉ាន់ស្មាន ដោយសារតែការសម្រួលរូបមន្តលាយ

## កំណត់សម្គាល់បន្ថែម៖

- សម្អាតផ្ទៃ និងឧបករណ៍នានាដោយប្រើសារធាតុសម្អាត ទឹក និងជក់ មុនពេលធ្វើការសម្លាប់មេរោគ។
- កុំលាយសារធាតុលាងសម្អាតប្រភេទអូសាវ៉ែល ជាមួយផលិតផលសម្អាតផ្សេងទៀត។
- លាយទឹកថ្នាំអូសាវ៉ែលថ្មីជារៀងរាល់ថ្ងៃ។
- ដាក់ស្លាកសម្គាល់លើដបផលិតផលសម្លាប់មេរោគ និងផលិតផលសម្អាតទាំងអស់។
- ប្រើរបៀបបាញ់ជាខ្សែទឹកនៅលើដបបាញ់ ដើម្បីកាត់បន្ថយហានិភ័យនៃការស្រូបចូល។
- ជៀសវាងប្រើទឹកថ្នាំអូសាវ៉ែល ដែលមានពណ៌ ឬមានក្លិនក្រអូប។ សារធាតុបន្ថែមដែលមាននៅក្នុងទឹកថ្នាំទាំងនោះ អាចបន្សល់ទុកនូវសំណល់នៅលើផ្ទៃសម្ភារៈ បើមិនបានលាងសម្អាតចេញឱ្យបានស្អាតល្អ។
- ដោយសារសារធាតុអូសាវ៉ែលកាត់ខ្លាំងចំពោះលោហៈ វាអាចបំផ្លាញសារធាតុស្អិត ឬឧបករណ៍នានា ប្រសិនបើត្រាំទុកចោលយូរពេក។ សូមអនុវត្តតាមការណែនាំរបស់អ្នកផលិតឧបករណ៍ទាក់ទងនឹងការប្រើប្រាស់ រួមទាំងប្រភេទថ្នាំសម្លាប់មេរោគដែលគួរប្រើប្រាស់ផងដែរ។

ឯកសារយោង៖

Public Health Ontario, The Guide to Infection Prevention and Control in Personal Service Settings, 3rd edition.

Adapted from Peel Public Health
Revised: 2023-08-23

simcoe muskoka DISTRICT HEALTH UNIT